00372396

001/១៨-០៧-២០០៧-អវតក/អជសង
E162/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 09 / 2009
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: 001/១៨-០៧-២០០៧-អវតក/អជសង
ភាគីដាក់ឯកសារ: សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣)
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: បារាំង (បកប្រែជាភាសាខ្មែរ)
កាលបរិច្ឆេទឯកសារ: ០១ កញ្ញា ២០០៩

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ៖ សារណាអំពីការធ្វើបណ្តឹងឧទ្ធរណ៍
ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩

---

**ដាក់ដោយ៖**
**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
អ្នកស្រី Martine JACQUIN
លោក Philippe CANONNE
អ្នកស្រី Annie DELAHAIE
អ្នកស្រី Elisabeth RABESANDRATANA
អ្នកស្រី Fabienne TRUSSES NAPROUS
អ្នកស្រី Christine MARTINAU

**ផ្ញើជូន៖**
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រមប្រធាន គង់ ស្រីម
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម យ៉ា ណារិន
ចៅក្រម Motoo NOGUCHI
ចៅក្រម Agnieska KLONOWIECKA-MILART
ចៅក្រម Chandra Nihal Jayasinghe

E162/2

**ចម្លងជូន**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មូណី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

**ជនជាប់ចោទ**

កាំងហ្គេច អ៊ាវ ហៅ ឌុច

**សហមេធាវីការពារ**

លោក ការ សាវុធ

លោក François Roux

**ភាគីដើមបណ្តឹងរដ្ឋប្បវេណី**

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យុង ផានិត

អ្នកស្រី ទី ស្រីនណា

អ្នកស្រី Silke STUDZINSKY

លោក Pierre Olivier Sur

លោក Karim KHAN

លោក Alain WERNER

កញ្ញា Brianne McGONIGLE

## I. សេចក្តីផ្តើម និងសេចក្តីសង្ខេប

1. តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសិទ្ធិរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរសាក្សីនិងអ្នកជំនាញស្តីអំពីអត្តចរិតរបស់ជនជាប់ចោទ[1] ។ ផ្ទុយទៅវិញ សិទ្ធិនេះត្រូវបានទទួលស្គាល់ជាសិទ្ធិត្រូវអនុវត្តក្នុងតុលាការ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតនូវការភន្តច្រលំក្នុងការអនុវត្តនូវបណ្តាវិធានអនុវត្តទាក់ទងនឹងសិទ្ធិរបស់ភាគីនៅក្នុងរឿងក្តី ជាពិសេសចំពោះវិធាន២៣ កថាខណ្ឌ៦ និងវិធាន៩១ កថាខណ្ឌ២ នៃវិធានផ្ទៃក្នុង ដែលមិនបានធ្វើការបែងចែកទាល់តែសោះចំពោះសិទ្ធិរវាងបណ្តាភាគីក្នុងរឿងក្តី ។ អង្គជំនុំជម្រះសាលាដំបូងបង្កនូវការភន្តច្រលំយ៉ាងច្បាស់ក្រឡែតចំពោះការថ្លឹងថ្លែងពិចារណា ដែលកំពុងធ្វើឱ្យប៉ះពាល់ដល់សមភាពនៃកម្លាំងរវាងភាគី ជាហេតុនាំឱ្យមានព្យសនកម្មដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។

## II. ច្បាប់ត្រូវអនុវត្ត

2. វិធាន ២៣ កថាខណ្ឌ ៦ វាក្យខណ្ឌ ក នៃវិធានផ្ទៃក្នុងទទួលស្គាល់ចាត់ទុកដើមបណ្តឹងរដ្ឋប្បវេណីជាភាគីមួយនៃរឿងក្តី ដូច្នេះហើយដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសិទ្ធិដូចគ្នាទៅនឹងភាគីដទៃ ៖

   *« ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអនុភាពដូចខាងក្រោម៖*
   *ជនរងគ្រោះក្លាយជាភាគីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ»*

3. វិធាន ៩៣ កថាខណ្ឌ ២ នៃវិធានផ្ទៃក្នុង ដែលមានខ្លឹមសារដូចមាត្រា៣២៦នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះ មិនបានធ្វើការបែងចែកផ្សេងពីគ្នាទាល់តែសោះរវាងភាគីនៃរឿងក្តី ៖

   *« សហព្រះអាជ្ញា ភាគីទាំងអស់ និងមេធាវី ត្រូវបានអនុញ្ញាតឱ្យសួរសំនួរដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង»*

4. អត្ថបទគតិយុត្តអន្តរជាតិ ជាពិសេស កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានទទួលស្គាល់នូវសិទ្ធិចំពោះរឿងក្តីប្រកបដោយសមធម៌

---

[1] ពង្រាងប្រតិចារិតនៃសវនាការចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ត្រង់ទំព័រ ៧៩

## III. មូលដ្ឋាននៃសម្អាងបណ្ដឹងឧទ្ធរណ៍

### ក- ការភន្ដច្រលំនៃអង្គច្បាប់

5. ការដែលច្រានចោលសិទ្ធិរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសួរសំណួរអ្នកជំនាញស្ដីពីអត្តបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ រួមទាំងសាក្សីទាក់ទងនឹងអត្តបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងទទួលគុណភាពច្បាប់អនុវត្ត ។

6. ជាការពិត វិធាន ២៣ កថាខណ្ឌ៦ វាក្យខណ្ឌ ក និងវិធាន ៩១ កថាខណ្ឌ២ នៃវិធានផ្ទៃក្នុង មិនបានធ្វើការបែងចែកទាល់តែសោះចំពោះភាពខុសគ្នារវាងភាគីនៃរឿងក្ដី ។ គោលការណ៍នេះក៏ត្រូវបានទទួលយកផងដែរដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលបានចែងវិធានដូចគ្នានៅក្នុងមាត្រា៣២៦ នោះ ។

7. នៅពេលការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានអនុភាពនោះ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ថាជាភាគីនៃរឿងក្ដី ហើយទទួលបាននូវសិទ្ធិដូចគ្នាទៅនឹងភាគីផ្សេងទៀតដែរ ។

8. នៅក្នុងការអនុវត្ត អង្គជំនុំជម្រះខ្លួនឯងបានទទួលស្គាល់ស្ថានភាពនៃអង្គហេតុនេះ ដោយបានផ្ដល់រយៈពេលដល់ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សួរសំណួរជនជាប់ចោទ ក៏ដូចជាសាក្សីនិងអ្នកជំនាញផ្សេងៗទាំងឡាយ ។

9. ដូច្នេះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើច្បាប់ដែលកំពុងអនុវត្ត ហើយដោយសារការណ៍នេះ សេចក្ដីសម្រេចត្រូវក្លាយជាអសុពលភាព ។

### ខ- ការភន្ដច្រលំច្បាស់ក្រឡែតនៃការថ្លឹងថ្លែងពិចារណា

10. ប៉ុន្ដែសម្អាងហេតុនៅតែមិនទាន់ផ្ដល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីនោះ សេចក្ដីសម្រេចថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ មិនអាចប្រមូលផ្ដុំនូវគ្រប់វិធានការនៃការដឹកនាំសវនាការបានដឡើយ នៅក្នុងខណៈដែលសេចក្ដីសម្រេចនេះផ្ទុយនឹងសិទ្ធិនៃការពារដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ខណៈដែលអន្ដរាគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនចូលរួមសម្ដែងដើម្បីស្វែងរកការពិត ។

11. តាមរយៈសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានលុបបំបាត់សិទ្ធិ ដែលដើមបណ្ដឹងរដ្ឋប្បវេណីមានអនុវត្តតាមពីដំបូងនៃរឿងក្ដី គឺសិទ្ធិស្នួរជនជាប់ចោទ សាក្សី និងអ្នកជំនាញការ ។

12. ប្រការចាត់ទុកជាការរំលោភមួយចំពោះគោលការណ៍នៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលជាធាតុជាសារវន្តនៃដំណើរក្ដីប្រកបដោយសមធម៌ ។

ហេតុដូចនេះអង្គជំនុំជម្រះសាលាដំបូងបានបង្កនូវការភន្តច្រលំយ៉ាងច្បាស់ក្រឡែតលើការថ្លឹងថ្លែងការពិចារណា ដែលបណ្ដាលឲ្យប៉ះពាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ខណៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានហាមឃាត់នូវសិទ្ធិរបស់ពួកគេដែលត្រូវផ្ដល់តាមដំណើរការនៃរឿងក្ដីប្រកបដោយសមធម៌ ។

**ហេតុដូច្នេះ**

សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ ស្នើសុំរំលាយសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩ ។

| **ភ្នំពេញ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩**<br><br>**ក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ៣** | |
|---|---|
| **សហមេធាវីChristine MARTINEAU** | **សហមេធាវី គីម ម៉េងឃី** |